


# ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

## របាយការណ៍ប្រចាំត្រីមាសទី ៤ ឆ្នាំ ២០២២

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)



# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ត្រីមាសទី៤ ឆ្នាំ ២០២២ *(បានត្រួតពិនិត្យឡើងវិញ)* | ឆ្នាំ ២០២១ *(បានធ្វើសវនកម្មរួច)* |
|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)** | | | |
| ទ្រព្យសកម្មសរុប | | ៦០.៧៥១.៧៣១ | ៦៦.៥៤០.៧៤៨ |
| បំណុលសរុប | | ២៩.២៣៦.៣៩០ | ២៩.៦៤៩.៨៥១ |
| មូលធនសរុប | | ៣១.៥១៥.៣៤១ | ៣៦.៨៩០.៨៩៧ |
| **លទ្ធផលហិរញ្ញវត្ថុ (ពាន់រៀល)** | | **ត្រីមាសទី៤ ឆ្នាំ ២០២២** *(បានត្រួតពិនិត្យឡើងវិញ)* | **ត្រីមាសទី៤ ឆ្នាំ ២០២១** *(មិនបានត្រួតពិនិត្យ និង មិនបានធ្វើសវនកម្ម)* |
| ចំណូលសរុប | | ១៦.៨៩៤.៦៧៥ | ១៩.៧២៧.២៨២ |
| ចំណេញ/(ខាត)មុនបង់ពន្ធ | | (១.១៧៧.៣៣៨) | ១.៨០៤.៣៧៩ |
| ចំណេញសុទ្ធ/(ខាត)ក្នុងការិយបរិច្ឆេទ | | (១.១៧៧.៣៣៨) | ១.៥១០.៦៥២ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | (១.១៨៩.៧៣៩) | ១.៥១០.៦៥២ |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី៤ ឆ្នាំ ២០២២** *(បានត្រួតពិនិត្យឡើងវិញ)* | **ឆ្នាំ ២០២១** *(បានធ្វើសវនកម្មរួច)* |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ១,៦៣ ដង | ២,១០ ដង |
| | អនុបាតចរន្តលឿន | ១,៤៣ ដង | ១,៦៧ ដង |
| | | **ត្រីមាសទី៤ ឆ្នាំ ២០២២** *(បានត្រួតពិនិត្យឡើងវិញ)* | **ត្រីមាសទី៤ ឆ្នាំ ២០២១** *(មិនបានត្រួតពិនិត្យ និង មិនបានធ្វើសវនកម្ម)* |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (%) | (១,៩៦) | ២,២៩ |
| | អនុបាតចំណេញធៀបនឹងមូលធន(%) | (៣,៧៨) | ៤,១១ |
| | អនុបាតគម្លាតចំណេញដុល(%) | ៤,៨៩ | ១៩,៦៤ |
| | អនុបាតគម្លាតចំណេញភាព(%) | (៧,០៤) | ៧,៦៦ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | (៦០) រៀល | ៨០ រៀល |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | (២,១៨) | ២.៥៩ |

## គ្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

❖ ស្ថានភាពហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ (ពាន់រៀល)




❖ ចំណេញ/ (ខាត) ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ (ពាន់រៀល)




❖ បម្រែបម្រួលថ្លៃភាគហ៊ុនក្នុងអំឡុងត្រីមាសទី៤ ឆ្នាំ២០២២



## សមាសភាពក្រុមប្រឹក្សាភិបាល



**លោក នាង វិធី**
ប្រធានក្រុមប្រឹក្សាភិបាល
និង នាយកគ្រប់គ្រង



**លោក ថៃ វ៉ាន់ថា**
អភិបាលមិនប្រតិបត្តិ



**លោកស្រី លឹម មុយលី**
អភិបាលមិនប្រតិបត្តិ និង នាយកហិរញ្ញវត្ថុ



**លោក ហ៊ុយ វ៉ាថារ៉ូ**
អភិបាលឯករាជ្យ



**លោក RAMI Bashir Asad Sharaf**
អភិបាលមិនប្រតិបត្តិ

# សេចក្តីថ្លែងរបស់ប្រធាន ក្រុមប្រឹក្សាភិបាល

តំណាងអោយក្រុមហ៊ុន **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** និងជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ របស់យើងខ្ញុំ ដោយគិតចាប់ពីថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២២ ជូនភាគីពាក់ព័ន្ធ និងសាធារណជនទាំងអស់។ ក្រុមហ៊ុនទទួលបានប្រាក់**ចំណូលសរុប ១៦ ៨៩៤ ៦៧៥ ពាន់រៀល** សម្រាប់ត្រីមាសទី៤ ដែលមានការថយចុះ ១៤,៣៦% បើធៀបនឹងប្រាក់ចំណូលសរុប ១៩ ៧២៧ ២៨២ ពាន់រៀល ក្នុងត្រីមាសទី៤ ឆ្នាំ២០២១។ ដោយឡែកក្រុមហ៊ុនបានខាតសម្មិតចំនួន (១ ១៨៩ ៧៣៩) ពាន់រៀល សម្រាប់ត្រីមាសនេះ។ ទ្រព្យសកម្មសរុបថយចុះ ៨,៧០ % បើធៀបនឹងឆ្នាំ ២០២១ ដែលថយពី ៦៦ ៥៤០ ៧៤៨ ពាន់រៀល ថយមក ៦០ ៧៥១ ៧៣១ ពាន់រៀលសម្រាប់ត្រីមាសទី ៤ ឆ្នាំ២០២២ ដោយសារការថយចុះនៃគណនីពាណិជ្ជត្រូវទទួល។



រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០២៣

ហត្ថលេខា និងត្រា

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក DBD ENGINEERING Plc.

**លោក នាង វិធី**

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង

## មាតិកា


**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ................ ii

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ................ iii

**សមាសភាពក្រុមប្រឹក្សាភិបាល** ................ iv

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ................ v

**ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ................ 1

ក-អត្តសញ្ញាណរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ................ 1

ខ-លក្ខណៈនៃធុរកិច្ច ................ 1

**ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ................ 3

ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ................ 3

ខ-រចនាសម្ព័ន្ធចំណូល ................ 5

**ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ................ 7

**ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ................ 8

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ................ 8

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ................ 11

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ................ 12

ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ................ 12

ង-ផលប៉ះពាល់នៃអតិផរណា ................ 13

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ................ 13

**ផ្នែកទី ៥៖ ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** ................ 14

**ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

## ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

### ក-អត្តសញ្ញាណរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** (ឌី ប៊ី ឌី) |
| ជាអក្សរឡាតាំង | DBD Engineering Plc. |
| អក្សរកូដ | KH១០០០១៥០០០៨ |
| ទីស្នាក់ការ | ដីឡូតិ៍ ៦៨ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរសព្ទ | (+៨៥៥) ៧៨ ៧០០ ៥៩៨ |
| គេហទំព័រ | www.dbdengineering.com |
| អ៊ីម៉ែល | services@dbdengineering.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៤០២៩ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៩៨ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ១២៣/២១ ស.ស.រ/ន.ម.ក. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ |
| ឈ្មោះបុគ្គលក្រុមហ៊ុន | លោក **នាង វិជី** |

### ខ-លក្ខណៈនៃធុរកិច្ច

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាក្រុមហ៊ុនពហុមុខងារ ផ្នែកវិស្វកម្ម និងសំណង់ដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌី ប៊ី ឌី ផ្តល់សេវាកម្មដូចជា សេវាគូសប្លង់ សាងសង់ដំឡើង និងថែទាំ ដែលសេវាកម្មទាំងនេះធ្វើឱ្យក្រុមហ៊ុនទទួលកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។ ឌី ប៊ី ឌី ទទួលបានកំណត់ត្រាល្អក្នុងការផ្តល់សេវាកម្ម និងផ្គត់ផ្គង់ផលិតផលប្រកបដោយគុណភាពខ្ពស់ដែលស្តែងបញ្ជាក់តាមរយៈការពេញចិត្ត និងការសរសើរពីសំណាក់អតិថិជនរបស់ខ្លួន។

អគ្គិសនី និងសំណង់



មេកានិច និងអគ្គិសនី



ការចុះត្រួតពិនិត្យ និងថែទាំអគារ



កម្តៅ ខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់



ឌី ប៊ី ឌី មានបុគ្គលិកជំនាញផ្នែកសេវាកម្ម និងការថែទាំ ដើម្បីធានា និងរក្សាគុណភាពជាប់រឹងមាំរបស់សំណង់អគារ និងការបំពាក់ឧបករណ៍ថ្មី ហើយបច្ចុប្បន្ននេះ ឌី ប៊ី ឌី បាននឹងកំពុងពង្រីកអាជីវកម្មផ្នែក ផលិតកម្មលើប្រព័ន្ធបំពង់គ្រឿងចក្រ ការថែរក្សារោងចក្រ និងឧបករណ៍។

## ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

នាដើមឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានគម្រោងដំបូងគេ គឺការសាងសង់ និងដំឡើងប្រព័ន្ធ MEP របស់អាគារ "WING OFFICE TOWER" ដែលមានទីតាំងស្ថិតនៅមហាវិថីព្រះមុនីវង្ស និងមហាវិថីកម្ពុជាក្រោមក្នុងសង្កាត់មនោរម្យខណ្ឌ ៧ មករា រាជធានីភ្នំពេញ។ គម្រោងនេះបានចាប់ផ្តើមធ្វើការសាងសង់ក្នុងឆ្នាំ ២០២២ និងបញ្ចប់គម្រោងក្នុងឆ្នាំ ២០២៣ នាពេលខាងមុខ។ បន្ថែមពីនេះក្រុមហ៊ុន ឌី ប៊ី ឌី ក៏សម្រេចទទួលយកគម្រោងធំមួយទៀតខាងផ្នែកសាងសង់ទាំងមូលទៅលើ គម្រោង "BIOMASS STEAM BOILER PLANT" ពីខាងក្រុមហ៊ុន BECIS ដែលនឹងផលិតថាមពលដោយចំហាយ និងផ្គត់ផ្គង់ទៅអោយ ក្រុមហ៊ុន HEINEKEN ។

ជាមួយគ្នានេះ ក្រុមហ៊ុន ឌី ប៊ី ឌី បានចូលរួមសាងសង់ និងបន្តសាងសង់គម្រោងធំៗមានដូចជា ផ្សារទំនើបអ៊ីអនទី១, ផ្សារទំនើបអ៊ីអនទី២, គម្រោងខុនដូ NORTH PARK, គម្រោង ជីប ម៉ុង សែនសុខ, គម្រោងផ្សារទំនើប ជីប ម៉ុង ៥៩៨, និងគម្រោងផ្សារទំនើប ជីប ម៉ុង ២៧១ ជាដើម។

បច្ចុប្បន្នក្រុមហ៊ុនកំពុងធ្វើការលើប្រព័ន្ធថ្មីសម្រាប់ការគ្រប់គ្រងធនធានមនុស្សដែលជួយឱ្យអ្នកគ្រប់គ្រងទទួលបានរបាយការណ៍ផ្ទាល់កាន់តែងាយស្រួលលើការរៀបចំ និងការត្រួតពិនិត្យកម្លាំងពលកម្ម ដើម្បីកាត់បន្ថយការខ្វះខាតកម្លាំងពលកម្ម។ បន្ថែមពីនេះ ក្រុមហ៊ុនក៏អនុវត្តមុខងារថ្មីនៅក្នុងប្រព័ន្ធគណនេយ្យបច្ចុប្បន្នផងដែរ ដើម្បីគ្រប់គ្រងការថ្លៃដើមសម្ភារៈ។

### គម្រោងថ្មី នៃត្រីមាសទី៤ ឆ្នាំ២០២២

| គម្រោង | ចំនួន (គិតបញ្ចូលពន្ធ) (ដុល្លារអាមេរិក) | កាលបរិច្ឆេទរំពឹងទុកនៃការបញ្ចប់គម្រោង |
|---|---|---|
| Wing Tower – AV Work Package | ៧៥២.០០០,០០ | ២០ មិថុនា ២០២៣ |
| FTB Bank Tower | ៤.៧៧៧.០០០,០០ | ៣១ ធ្នូ ២០២៤ |

### គម្រោងស្ថិតក្នុងដំណើរការ

| គម្រោង | កាលបរិច្ឆេទចាប់ផ្តើមគម្រោង | លទ្ធផលសម្រេចបាន |
|---|---|---|
| WING Tower | ៦ មករា ២០២២ | ២៧% |
| DBD New HQ | ៧ ធ្នូ ២០២១ | ៧៧% |
| WING Bank Branch | ១ កញ្ញា ២០២១ | ៩៨% |
| Chip Mong 271 Mega Mall | កក្កដា ២០២០ | ៩៩,៩៥% |
| Tenant Market Place | ៧ មិថុនា ២០២២ | ៩៩,៥០% |

| | | |
|---|---|---|
| Tenant Food Court | ៦ សីហា ២០២២ | ៩៨,០១% |
| Tenant Cinema | ៥ សីហា ២០២២ | ៧៥,៨៧% |
| Tenant Paradise | ៣០ កញ្ញា ២០២២ | ៩៧,៩៧% |
| Decathlon Aeon 3 | ១០ តុលា ២០២២ | ៧៦,៤០% |
| Tenant CMG Office | | ៧៨% |
| Tenant CMRT Office | | ៧៩% |




❖ **គម្រោង BIOMASS STEAM BOILER PLANT**




**គម្រោងអាគារ WING OFFICE TOWER**



គម្រោង CHIP MONG MEGA MALL 271




គម្រោង CHIP MONG SENSOK MALL




គម្រោង CHIP MONG 598 MALL



គម្រោង TRIBE HOTEL Phnom Penh

## ខ-រចនាសម្ព័ន្ធចំណូល

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានប្រភពចំណូលពីរ ដែលចំណូលទី ១ គឺបានមកពីគម្រោងសាងសង់ ដែលជាប្រភពចម្បង ក្នុងនោះរួមបញ្ចូលនូវគម្រោងថ្មី និងការងារជួសជុល និងការថែទាំ។ ប្រភពចំណូលទី ២ គឺបានមកពីការលក់សម្ភារៈគម្រោង ដែលវាជាផ្នែកតូចមួយរបស់ចំណូលសរុប។ ទោះបីជាយ៉ាងណាក៏ដោយ ប្រាក់ចំណូលពីការលក់សម្ភារៈគម្រោង នឹងមានការកើនឡើងបន្ទាប់ពីក្រុមហ៊ុនពង្រីកនូវផលិតកម្មបំពង់របស់ខ្លួន។ ក្រុមហ៊ុន ឌី ប៊ី ឌី នឹងធ្វើការលក់ផលិតផលនេះ ដែលសព្វថ្ងៃនេះក្រុមហ៊ុនផលិតសម្រាប់តែផ្គត់ផ្គង់គម្រោងសាងសង់របស់ខ្លួនប៉ុណ្ណោះ។

| ល.រ | ប្រភពចំណូល | ត្រីមាសទី៤ ឆ្នាំ២០២២ | | ត្រីមាសទី៤ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ |
| ១ | ចំណូលពីគម្រោងសាងសង់ | ១៦.៨៤៥.៨៤៩ | ៩៩,៧១% | ១៨.២៦៤.៧៤៨ | ៩២,៥៩% |
| ២ | ចំណូលពីការលក់ទំនិញ | ៤៨.៨២៦ | ០,២៩% | ១.៤៦២.៥៣៤ | ៧,៤១% |
| ចំណូលសរុប | | **១៦.៨៩៤.៦៧៥** | **១០០%** | **១៩.៧២៧.២៨២** | **១០០%** |

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី មានចំណូលចំនួន ១៦.៨៩៤.៦៧៥ ពាន់រៀល ដែលថយចុះចំនួន ២.៨៣២.៦០៧ ពាន់រៀល ស្មើនឹង ១៤,៣៦ ភាគរយ បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២១។ ការថយចុះនេះ បណ្តាលមកពីចំណូលពីគម្រោងសាងសង់ថយចុះចំនួន ៧,៧៧ ភាគរយ និងចំណូលពីការលក់ទំនិញថយចុះចំនួន ៩៦,៦៦ ភាគរយ។

## ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រូវពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។

## ផ្នែកទី ៤.- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដោយគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបានជះឥទ្ធិពលទៅ លើប្រាក់ចំណេញរបស់ក្រុមហ៊ុន ឌី ប៊ី ឌី តែប៉ុណ្ណោះ។

### ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានបង្កើតឡើងនៅឆ្នាំ១៩៩៨ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនម៉ៅការសាងសង់ឯកទេសផ្នែក MEP និងសំណង់ស៊ីវិល ដែលផ្តល់សេវាកម្មលើផ្នែកមេកានិច អគ្គិសនី ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ម៉ាស៊ីនត្រជាក់ បន្ទប់ត្រជាក់ HVAC និងថែទាំអគារ។

#### ១-ការវិភាគចំណូល

ប្រភពចំណូលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក គឺបានពីសេវាសាងសង់ និងសេវាថែទាំ រួមទាំងការងារ MEP និងការងារសំណង់ស៊ីវិល ហើយចំណូលសរុបត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយធ្វើការបែងចែកជា ៣ (បី) ផ្នែកដូចជា៖ (១).ការសាងសង់ និងសេវាកម្មថែទាំ, (២).ការលក់ទំនិញ និង (៣).ចំណូលផ្សេងៗ។ ចំណូលត្រូវបានទទួលស្គាល់នៅពេលក្រុមហ៊ុន ឌី ប៊ី ឌី បានបំពេញការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាអតិថិជនបានរួចរាល់។ ដើម្បីទទួលស្គាល់ចំណូល ក្រុមហ៊ុន ឌី ប៊ី ឌី បានអនុវត្ត ៥ ជំហាន គឺ៖

១.កំណត់កិច្ចសន្យាជាមួយអតិថិជន

២.កំណត់ពីការអនុវត្តកាតព្វកិច្ច

៣.កំណត់ពីថ្លៃប្រតិបត្តិការ

៤.ការបែងចែកថ្លៃប្រតិបត្តិការធៀបនឹងការអនុវត្តកាតព្វកិច្ច

៥.ទទួលស្គាល់ចំណូលនៅពេល/ការអនុវត្តកាតព្វកិច្ចត្រូវបានពេញចិត្ត។

### ២-ការវិភាគចំណូលតាមផ្នែក

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី មានចំណូលចំនួន ១៦.៨៩៤.៦៧៥ ពាន់រៀល ដែលថយចុះចំនួន ២.៨៣២.៦០៧ ពាន់រៀល ស្មើនឹង ១៤,៣៦ ភាគរយ បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២១។ ការថយចុះនេះ បណ្តាលមកពីចំណូលពីគម្រោងសាងសង់ថយចុះចំនួន ៧,៧៧ ភាគរយ និងចំណូលពីការលក់ទំនិញថយចុះចំនួន ៩៦,៦៦ ភាគរយ។

### ៣-ការវិភាគគម្លាតចំណេញដុល

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានចំណេញដុលចំនួន ៨២៦.៩១៩ ពាន់រៀល ដែលថយចុះចំនួន ៣.០៤៧.២៦០ ពាន់រៀល ស្មើនឹង ៧៨,៦៦ ភាគរយ បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២១។ ការខាតនេះបណ្តាលមកពីការថយចុះនៃចំណូល។

### ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| តារាងសង្ខេប ប្រាក់ចំណេញ | ត្រីមាសទី៤ ឆ្នាំ២០២២ (ពាន់រៀល) | ត្រីមាសទី៤ ឆ្នាំ២០២១ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណេញដុល | ៨២៦.៩១៩ | ៣.៨៧៤.១៧៩ | (៣.០៤៧.២៦០) | -៧៨,៦៦% |
| ចំណូលផ្សេងៗ | ៧.០២៥ | ៣៨.៤៩៥ | (៣១.៤៧០) | -៨១,៧៥% |
| ចំណាយប្រតិបត្តិការ | (១.៦៤០.៤៩៧) | (១.៦០០.១៩០) | ៤០.៣០៧ | ២,៥២% |
| ចំណាយហិរញ្ញវត្ថុ | (៣៧០.៧៨៥) | (៥០៨.១០៥) | (១៣៧.៣២០) | -២៧,០៣% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **(១.១៧៧.៣៣៨)** | **១.៨០៤.៣៧៩** | **(២.៩៨១.៧១៧)** | **-១៦៥,២៥%** |

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ខាតមុនបង់ពន្ធចំនួន (១.១៧៧.៣៣៨) ពាន់រៀល ដែលការខាតនេះបានកើនឡើងចំនួន ២.៩៨១.៧១៧ ពាន់រៀល ស្មើនឹង ១៦៥,២៥ ភាគរយ បើធៀបនឹងត្រីមាសទី ៤ ឆ្នាំ២០២១។ មូលហេតុចម្បងនៃការកើនឡើងនៃការខាតនេះ ដោយសារតែមានការថយចុះនូវចំណូលចំនួន ១៤,៣៦ ភាគរយ និងចំណូលផ្សេងៗមានការថយចុះចំនួន ៨១,៧៥ ភាគរយ ។

### ៥-ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| តារាងសង្ខេបប្រាក់ចំណេញ | ត្រីមាសទី៤ ឆ្នាំ២០២២ (ពាន់រៀល) | ត្រីមាសទី៤ ឆ្នាំ ២០២១(ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ | (១.១៧៧.៣៣៨) | ១.៨០៤.៣៧៩ | (២.៩៨១.៧១៧) | -១៦៥,២៥% |
| ចំណាយពន្ធលើប្រាក់ចំណូល | - | (២៩៣.៧២៧) | (២៩៣.៧២៧) | -១០០ % |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **(១.១៧៧.៣៣៨)** | **១.៥១០.៦៥២** | **(២.៦៨៧.៩៩០)** | **-១៧៧,៩៤ %** |

ចំពោះពន្ធលើប្រាក់ចំណូល ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបង់ចំនួន ២០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធ ដោយកាត់កងជាមួយប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ ចំនួន ១ ភាគរយ នៃចំណូលប្រចាំឆ្នាំសរុប។

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានខាតក្នុងការិយបរិច្ឆេទចំនួន (១.១៧៧.៣៣៨) ពាន់រៀល ដែលការខាតនេះបានកើនឡើងចំនួន ២.៦៨៧.៩៩០ ពាន់រៀល ស្មើនឹង ១៧៧,៩៤ ភាគរយ បើធៀបនឹងត្រីមាសទី៤ ឆ្នាំ ២០២១។ មូលហេតុចម្បងនៃការខាតនេះ គឺដោយសារក្រុមហ៊ុនមានការកើនឡើងនៃខាតមុនបង់ពន្ធ។

### ៦-ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានលទ្ធផលខាតលម្អិតក្នុងការិយបរិច្ឆេទចំនួន (១.១៨៩.៧៣៩)ពាន់រៀល ដែលការខាតនេះបានកើនឡើងចំនួន ២.៧០០.៣៩១ ពាន់រៀល ស្មើនឹង ១៧៨,៧៦ ភាគរយ បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២១។ មូលហេតុចម្បងនៃការខាតនេះ គឺដោយសារក្រុមហ៊ុនមានការកើនឡើងនៃខាតមុនបង់ពន្ធ។

### ៧-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលគួរឱ្យកត់សម្គាល់ឡើយ។

**ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានវិភាគកត្តាសំខាន់ៗដូចខាងក្រោម ដែលអាចមានផលប៉ះពាល់ដល់លទ្ធភាពរកប្រាក់ចំណេញដល់ក្រុមហ៊ុន។

**១-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់**

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទិន្នន័យសំណង់ទូទាំងប្រទេសមានចំនួន ៤.២៧៦ គម្រោង ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន ៧.២៨៩.៧៦៥ ម៉ែត្រការ៉េ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ២.៩៧២.២៦០.៩២៨ ដុល្លារអាមេរិក មានការថយចុះចំនួន ៤៤,២៧ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ មានចំនួន ៤.៣០៣ គម្រោង មានផ្ទៃក្រឡាកម្រាលសំណង់ចំនួន ១២.៩៩៨.០៧២ ម៉ែត្រការ៉េ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ៥.៣៣៣.៧៩៨.៥២៥ ដុល្លារអាមេរិក។

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក គឺជាក្រុមហ៊ុនសំណង់ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើការផ្តល់សេវាកម្ម MEP ដែលមានដូចជា (១)ផ្នែកមេកានិច និងអគ្គិសនី (២)ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ (៣)កម្តៅខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់ (៤) សំណង់ស៊ីវិល និង (៥) ការថែទាំអគារ។

**២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានរួមបញ្ចូលការឡើងអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើរដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើតម្លៃសម្ភារៈកើនឡើងខ្លាំង វានឹងធ្វើឱ្យក្រុមហ៊ុនខាតបង់។

**៣-ការវិភាគលើពន្ធ**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានទទួលនូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូល ៥០ ភាគរយ សម្រាប់រយៈពេល៣ឆ្នាំ ដោយគិតចាប់ពីឆ្នាំ ២០២២ ដល់ ២០២៤។ ដោយអនុលោមតាមច្បាប់ពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌី ប៊ី ឌី មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធ។ ក្រៅពីពន្ធលើប្រាក់ចំណេញ ក្រុមហ៊ុនក៏ត្រូវបង់ពន្ធអប្បបរមាផងដែរ។ ពន្ធអប្បបរមា ជាពន្ធប្រចាំឆ្នាំជាមួយនឹងអត្រា ១ ភាគរយ លើចំណូលប្រចាំឆ្នាំសរុប ដោយរួមបញ្ចូលពន្ធគ្រប់ប្រភេទទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម និងដោយមិនគិតពីស្ថានភាពចំណេញ ឬខាតរបស់ក្រុមហ៊ុនឡើយ។ បន្ថែមពីនេះ ក្រុមហ៊ុនបាន

គណនាអាករលើតម្លៃបន្ថែមចំនួន ១០ ភាគរយ នៅលើវិក័យបត្រដែលចេញទៅឱ្យអតិថិជន។ អាករលើតម្លៃបន្ថែមត្រូវបានកាត់កងជាមួយអាករលើតម្លៃបន្ថែមលើធាតុចូល ១០ ភាគរយ ដែល ក្រុមហ៊ុនបានទូទាត់ទៅអ្នកផ្គត់ផ្គង់នូវរាល់ការទិញទំនិញ។ ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់នៅអត្រា ៤ ភាគរយ នៃប្រាក់បញ្ញើចរន្ត ដែលត្រូវបានកាត់ទុកដោយធនាគារ, បង់ពន្ធកាត់ទុកលើប្រាក់បំណាច់ ឬលាភការ របស់ក្រុមប្រឹក្សាភិបាល នៅអត្រា ១៥ ភាគរយ, បង់ពន្ធកាត់ទុកលើការចំណាយពាក់ព័ន្ធនឹងសេវាប្រឹក្សាយោបល់នៅ អត្រា ១៤ ភាគរយ (អនិវាសនជន) និង អត្រា ១៥ ភាគរយ (និវាសនជន), និងបង់ពន្ធកាត់ទុកលើចំណូលពីការជួលនៅអត្រា ១០ ភាគរយ។ ជាមួយគ្នានេះ ក្រុមហ៊ុនក៏មានកាតព្វកិច្ចបង់ពន្ធលើការនាំចូលលើសម្ភារៈ និងវត្ថុធាតុដើមនូវអត្រា ៧ ភាគរយទៅ ៣៥ ភាគរយ ផ្អែកលើប្រភេទទំនិញ។

**៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ គណៈគ្រប់គ្រងយល់ថាក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

**គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល**

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ប្រាក់ចំណូលរបស់ ឌី ប៊ី ឌី ពីការលក់សម្ភារៈមានការថយចុះយ៉ាងគួរឲ្យកត់សម្គាល់ ហើយប្រាក់ចំណូលពីការសាងសង់ក៏មានការថយចុះ ដោយសារនៅក្នុងត្រីមាសនេះ ឌី ប៊ី ឌី មានគម្រោងធំដែលកំពុងសាងសង់មួយគឺ "Chip Mong Mega Mall 271" ដែលគ្រោងនឹងបញ្ចប់នាពេលឆាប់ៗ ហើយចំណូលដែលបានមកពីគម្រោងនេះមិនសូវច្រើនទេ។ គម្រោងធំដ៏ទៃទៀតដូចជា "Wing Tower" ទើបតែចាប់ផ្តើម។ នៅក្នុងឆ្នាំ២០២២ នេះដែរ ឌី ប៊ី ឌី ក៏បានសាងសង់អគារការិយាល័យកណ្តាល និងឃ្លាំងសម្រាប់ដាក់សម្ភារៈ ដែលការចំណាយនេះត្រូវបានកត់ត្រាចូលជាទ្រព្យសកម្មរយៈពេលវែងរបស់ក្រុមហ៊ុន ដូច្នេះទើបប្រាក់ចំណូលមានការថយចុះបើធៀបទៅនឹងត្រីមាសទី៤ នៃឆ្នាំ២០២១។

**ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ**

**១-ផលប៉ះពាល់នៃអត្រាប្តូរប្រាក់**

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុជារូបិយប័ណ្ណបរទេសផ្សេងទៀតទេ លើកលែងតែមានទឹកប្រាក់តូចមួយចំនួនសម្រាប់គណនីអ្នកផ្គត់ផ្គង់ ដែលត្រូវបង់ជារូបិយប័ណ្ណថៃបាត (THB) និង អឺរ៉ូ (EUR) ហើយរាល់កម្ចីទាំងអស់របស់ក្រុមហ៊ុនមានអត្រាថេរ ដូច្នេះក្រុមហ៊ុនមិនមានផលប៉ះពាល់ខ្លាំងពីការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេស និងអត្រាការប្រាក់ទេ។

**២-ផលប៉ះពាល់នៃអត្រាការប្រាក់**

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ុនជីនារីង ម.ក មិនទទួលរងហានិភ័យពាក់ព័ន្ធនឹងអត្រាការប្រាក់នោះទេ។

**៣-ផលប៉ះពាល់នៃថ្លៃទំនិញ**

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ុនជីនារីង ម.ក មិនមានផលប៉ះពាល់ជាសារវន្តលើថ្លៃទំនិញនោះទេ។

**ង-ផលប៉ះពាល់នៃអតិផរណា**

ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ុនជីនារីង ម.ក បានរួមបញ្ចូលការកើនឡើងនៃអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើរដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។

**ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល**

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យអចលនទ្រព្យ និងសំណង់គឺជាកត្តាចម្បងមួយជំរុញកំណើនសេដ្ឋកិច្ច។ យោងតាមរបាយការណ៍របស់ CBRE ទស្សនវិស័យទីផ្សារអចលនទ្រព្យកម្ពុជាឆ្នាំ ២០១៩ ឧស្សាហកម្មសំណង់បានកើនឡើង ១៨,១ ភាគរយ រីឯនៅក្នុងឆ្នាំ ២០១៨ ចំនួនខុនដូកើនឡើងប្រហែល ១២០ ភាគរយ។ ខណៈពេលដែលកត្តាកំណើនសេដ្ឋកិច្ចចម្រុះចូលទៅក្នុងដំណើរការដ៏រឹងមាំនៃឧស្សាហកម្មសំណង់ ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជាកត្តាជំរុញដ៏សំខាន់មួយនៃឧស្សាហកម្មនេះ។ ក្នុងឆ្នាំ២០១៩ FDI នៅកម្ពុជាមានចំនួន ១០,៦ ភាគរយនៃទិន្នផលក្នុងស្រុកសរុប (GDP)សរុប។ ក្នុងឆ្នាំ២០១៨ ការវិនិយោគផ្ទាល់ពីបរទេសបានឈានដល់កម្រិតខ្ពស់បំផុតដោយកើនឡើង ១០,៧ ភាគរយ ឬ ៣០០ លានដុល្លាអាមេរិក ពី ២,៨ ពាន់លានដុល្លាអាមេរិក ក្នុងឆ្នាំ២០១៧ ដល់ ៣,១ ពាន់លានដុល្លាអាមេរិក ក្នុងឆ្នាំ២០១៨ (ធនាគារពិភពលោក)។ ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ក្នុងស្រុក ការកែតម្រូវទីផ្សារអចលនទ្រព្យបន្ទាប់ពីការសាងសង់អូសបន្លាយពេលយូរ និងការរីកដុះដាលនៃអចលនទ្រព្យ ការផ្តល់ឥណទានកើនឡើងដល់វិស័យសំណង់/អចលនទ្រព្យ/កម្ចីទិញផ្ទះ (ដែលថ្មីៗនេះពឹងផ្អែកខ្លាំងលើការវិនិយោគរបស់ចិន) និងឥណទាន គឺជាចំណុចខ្សោយនៃឧស្សាហកម្មបច្ចុប្បន្ន។

## ផ្នែកទី ៥.-ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

- ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានព័ត៌មានគួរឱ្យកត់សម្គាល់ផ្សេងទៀតក្រៅពីព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍នេះទេ។

## ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង

កាលបរិច្ឆេទ៖ ថ្ងៃទី២៤ខែកុម្ភៈ ឆ្នាំ២០២៣

បានអាន និងឯកភាព

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING Plc.
KINGDOM OF CAMBODIA

______________________

លោក នាង វិធី

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
# និង
# ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

# ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ត្រីមាស និង
សម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែដែលបានបញ្ចប់

# មាតិកា


| | ទំព័រ |
|---|---|
| **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** | ១ |
| **ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** | |
| របាយការណ៍ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២ - ៣ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ៤ - ៥ |
| របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល | ៦ - ៧ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | ៨ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល | ៩ - ១០ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ១១ - ៣២ |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ភ្ជាប់ជាមួយនឹងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលមានរបាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ត្រីមាស និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែដែលបានបញ្ចប់ រួមទាំងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្ត ស្របតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING Plc.
KINGDOM OF CAMBODIA

_______________________________

**លោក នាង វិធី**
**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣

Grant Thornton

# របាយការណ៍ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

**ហ្ក្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

## ជូនចំពោះភាគហ៊ុនិករបស់
## ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

យើងខ្ញុំបានធ្វើការត្រួតពិនិត្យទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងរបាយការណ៍ចំណូលលម្អិតចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ត្រីមាស និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែដែលបានបញ្ចប់ រួមទាំងសេចក្តីពន្យល់លើកំណត់សម្គាល់ ("ព័ត៌មានហិរញ្ញវត្ថុ")។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញជូននូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើសេចក្តីសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ដោយផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យដោយអនុលោមតាមស្តង់ដារអន្តរជាតិនៃកម្ពុជា លើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី *ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់អង្គភាព*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរួមមាន ការចោទសួរជាចម្បងទៅកាន់បុគ្គលដែលទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុរួមទាំងការអនុវត្តតាមនីតិវិធីក្នុងការវិភាគ និងនីតិវិធីក្នុងការត្រួតពិនិត្យផ្សេងទៀត។ ការត្រួតពិនិត្យនេះមានវិសាលភាពតិចជាងការធ្វើសវនកម្ម ដែលធ្វើឡើងដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ដូច្នេះហើយ យើងខ្ញុំមិនធានាថា យើងខ្ញុំនឹងដឹងអំពីបញ្ហាសំខាន់ៗទាំងអស់ដែលអាចនឹងត្រូវបានកំណត់អត្តសញ្ញាណដូចការធ្វើសវនកម្មនោះទេ។ ហេតុនេះហើយ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មទេ។

## សេចក្តីសន្និដ្ឋាន

ផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ មិនមានបញ្ហាណាមួយគួរឱ្យកត់សម្គាល់ ដែលជាហេតុធ្វើឱ្យយើងខ្ញុំមានការជឿជាក់ថា ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន មិនបានរៀបចំត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* នោះទេ។

Grant Thornton

## បញ្ហាផ្សេងៗ

ព័ត៌មានប្រៀបធៀបក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺអាស្រ័យទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ព័ត៌មានប្រៀបធៀបសម្រាប់ត្រីមាស និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែដែលបានបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ក្នុងរបាយការណ៍ចំណូលលម្អិត របាយការណ៍លំហូរសាច់ប្រាក់ រួមទាំងសេចក្ដីពន្យល់ក្នុងកំណត់សម្គាល់ មិនត្រូវបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្មឡើយ។

Grant Thornton

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣

គណនេយ្យករជំនាញ និងសវនករប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | (បានធ្វើសវនកម្ម) | |
|---|---|---|---|---|---|
| | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ - សុទ្ធ | ៦ | **៤.១០៣.៧៣៨** | **១៦.៨៩៥.០៨៩** | ២.៦៤៣.០៦២ | ១០.៧៦៧.៨៣៥ |
| ទ្រព្យសកម្មអរូបី - សុទ្ធ | ៧ | **៤៣.៧៤៥** | **១៨០.០៩៨** | ៣៣.៩៨៦ | ១៣៨.៤៥៩ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម - សុទ្ធ | ៨ | **-** | **-** | ៣២.៧៤៥ | ១៣៣.៤០៣ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | ៩ | **២០.១០០** | **៨២.៧៥២** | ២០.០៥០ | ៨១.៦៨៤ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **៤.១៦៧.៥៨៣** | **១៧.១៥៧.៩៣៩** | ២.៧២៩.៨៤៣ | ១១.១២១.៣៨១ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | ១៥ | **៤.៣៣៨.៧៧២** | **១៧.៨៦២.៧២៤** | ៣.៧៩១.៣៦៦ | ១៥.៤៤៦.០២៥ |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | ១៤ | **១.០៦២.២៣៧** | **៤.៣៧៣.២៣០** | ៩៤៦.៩៦២ | ៣.៨៥៧.៩២៣ |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | ២៦ | **១៣៦.២៧០** | **៥៦១.០២៤** | ១៣៤.៤២១ | ៥៤៧.៦៣១ |
| សន្និធិ - សុទ្ធ | ១៣ | **១.២៧៤.១៣២** | **៥.២៤៥.៦០១** | ២.១៦៧.២៥៨ | ៨.៨២៩.៤០៩ |
| គណនីពាណិជ្ជត្រូវទទួល | ១២ | **៣.១៦៥.៧៧៣** | **១៣.០៣៣.៤៨៧** | ៦.២៧៣.០៥៧ | ២៥.៥៥៦.៤៣៤ |
| ប្រាក់តម្កល់ធានា | ១១ | **៥៩០.០៨០** | **២.៤២៩.៣៥៩** | ៦៥.០០០ | ២៦៤.៨១០ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០ | **២១.៤៦៤** | **៨៨.៣៦៧** | ២២៥.១១៩ | ៩១៧.១៣៥ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១០.៥៨៨.៧២៨** | **៤៣.៥៩៣.៧៩២** | ១៣.៦០៣.១៨៣ | ៥៥.៤១៩.៣៦៧ |
| **ទ្រព្យសកម្មសរុប** | | **១៤.៧៥៦.៣១១** | **៦០.៧៥១.៧៣១** | ១៦.៣៣៣.០២៦ | ៦៦.៥៤០.៧៤៨ |
| **បំណុល និងមូលធន** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | **៤.៦១៥.៣៨៥** | **១៨.៧៨៩.៦៨៧** | ៤.៦១៥.៣៨៥ | ១៨.៧៨៩.៦៨៧ |
| បុព្វលាភដើមទុន | ១៦ | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ |
| ប្រាក់ចំណេញរក្សាទុក | | **៨៨១.៣៩០** | **៣.៧១៨.៩៦៨** | ២.២៨១.៦៦៤ | ៩.៤៤១.៨៨៧ |
| ការប្តូររូបិយប័ណ្ណបម្រុងទុក | | **-** | **២២០.៣១៦** | - | (១២៧.០៤៧) |
| **មូលធនសរុប** | | **៧.៦៥៤.៩២៩** | **៣១.៥១៥.៣៤១** | ៩.០៥៥.២០៣ | ៣៦.៨៩០.៨៩៧ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី - ដកចេញចំណែករយៈពេលខ្លី | ១៧ | **៥៩៩.៨៦៣** | **២.៤៦៩.៦៣៦** | ៨១១.៣២០ | ៣.៣០៥.៣១៨ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | (បានធ្វើសវនកម្ម) ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **បំណុលរយៈពេលខ្លី** | | | | | |
| ប្រាក់កម្ចី | ១៧ | **៨៩៣.៧៨៣** | **៣.៦៧៩.៧០៥** | ២.៥១៩.០១១ | ១០.២៦២.៤៥១ |
| គណទានវិបារូបន៍ | ១៨ | **២.៤១០.៩៨៤** | **៩.៩២៦.០២០** | ១.៨៧១.១១២ | ៧.៦២២.៩១០ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១៩ | **១.០៨០.២៤៤** | **៤.៤៤៧.៣៦៥** | ១.៨៣១.២១៥ | ៧.៤៦០.៣៧០ |
| បំណុលភតិសន្យា | ៨ | **-** | **-** | ៤៨.៥០៩ | ១៩៧.៦២៦ |
| បំណុលកិច្ចសន្យា | ១៥ | **២.១០៥.២៥៤** | **៨.៦៦៧.៣៣១** | ១៦១.៨៨០ | ៦៥៩.៤៩៩ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ២៥ | **១១.២៥៤** | **៤៦.៣៣៣** | ៣៤.៧៧៦ | ១៤១.៦៧៧ |
| **បំណុលរយៈពេលខ្លី** | | **៦.៥០១.៥១៩** | **២៦.៧៦៦.៧៥៤** | ៦.៤៦៦.៥០៣ | ២៦.៣៤៤.៥៣៣ |
| **បំណុលសរុប** | | **៧.១០១.៣៨២** | **២៩.២៣៦.៣៩០** | ៧.២៧៧.៨២៣ | ២៩.៦៤៩.៨៥១ |
| **មូលធន និងបំណុលសរុប** | | **១៤.៧៥៦.៣១១** | **៦០.៧៥១.៧៣១** | ១៦.៣៣៣.០២៦ | ៦៦.៥៤០.៧៤៧ |

# របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល

| | កំណត់សម្គាល់ | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ត្រីមាសដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) សម្រាប់ត្រីមាសដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|
| ចំណូល | ២០ | **៤.០៩១.៧១១** | **១៦.៨៩៤.៦៧៥** | ៤.៨៤២.២៣៩ | ១៩.៧២៧.២៨២ |
| ថ្លៃដើមទំនិញ និងសេវាកម្ម | ២១ | **(៣.៨៩១.៤៤០)** | **(១៦.០៦៧.៧៥៦)** | (៣.៨៩១.២៨៧) | (១៥.៨៥៣.១០៣) |
| **ចំណេញដុល** | | **២០០.២៧១** | **៨២៦.៩១៩** | ៩៥០.៩៥២ | ៣.៨៧៤.១៧៩ |
| ចំណូលផ្សេងៗ - សុទ្ធ | ២៣ | **១.៧០១** | **៧.០២៥** | ៩.៤៤៩ | ៣៨.៤៩៥ |
| ចំណាយប្រតិបត្តិការ | ២២ | **(៣៩៧.៣១១)** | **(១.៦៤០.៤៩៧)** | (៣៩២.៧៨១) | (១.៦០០.១៩០) |
| ចំណាយហិរញ្ញវត្ថុ | ២៤ | **(៨៩.៨០០)** | **(៣៧០.៧៨៥)** | (១២៤.៧១៩) | (៥០៨.១០៥) |
| **(ខាត)/ចំណេញមុនបង់ពន្ធ** | | **(២៨៥.១៣៩)** | **(១.១៧៧.៣៣៨)** | ៤៤២.៩០១ | ១.៨០៤.៣៧៩ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៥ | **-** | **-** | (៧២.០៩៨) | (២៩៣.៧២៧) |
| **(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ** | | **(២៨៥.១៣៩)** | **(១.១៧៧.៣៣៨)** | ៣៧០.៨០៣ | ១.៥១០.៦៥២ |
| ចំណូល/(ខាត)លម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | | **-** | **(១២.៤០១)** | - | - |
| **(ខាត)/ចំណូលលម្អិតផ្សេងៗសរុបក្នុងការិយបរិច្ឆេទ** | | **(២៨៥.១៣៩)** | **(១.១៨៩.៧៣៩)** | ៣៧០.៨០៣ | ១.៥១០.៦៥២ |

(ខាត)/ចំណេញក្នុងមួយសន្លឹកហ៊ុន ដែលបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| (ខាត)/ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន | **២៩** | (0.0២) | (0.0៦) | 0.0២ | 0.0៨ |
| (ខាត)/ចំណេញថយចុះក្នុងមួយភាគហ៊ុន | **២៩** | (0.0២) | (0.0៦) | 0.0២ | 0.0៨ |

# របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | (បានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| ចំណូល | ២០ | **១៤.៣១៦.៧៨៣** | **៥៨.៥១២.៦៩២** | ១៧.៩៦៤.២២៨ | ៧៣.០៧៨.៤៨០ |
| ថ្លៃដើមទំនិញ និងសេវាកម្ម | ២១ | **(១៣.៦០៤.០៥៧)** | **(៥៥.៥៩៩.៧៨១)** | (១៥.៤០៩.៤១០) | (៦២.៦៨៥.៤៨០) |
| **ចំណេញដុល** | | **៧១២.៧២៦** | **២.៩១២.៩១១** | ២.៥៥៤.៨១៨ | ១០.៣៩៣.០០០ |
| ចំណូលផ្សេងៗ - សុទ្ធ | ២៣ | **៧.៣១៧** | **២៩.៩០៥** | ២៨.០៦៣ | ១១៤.១៦០ |
| ចំណាយប្រតិបត្តិការ | ២២ | **(១.៥៥៧.៥៨៧)** | **(៦.៣៦៥.៨៥៨)** | (១.៤៨៣.៥៧៥) | (៦.០៣៥.១៨៣) |
| ចំណាយហិរញ្ញវត្ថុ | ២៤ | **(៣៥៤.៦០២)** | **(១.៤៤៩.២៥៨)** | (៥០៦.៨៧០) | (២.០៦១.៩៤៧) |
| **(ខាត)/ចំណេញមុនបង់ពន្ធ** | | **(១.១៩២.១៤៦)** | **(៤.៨៧២.៣០០)** | ៥៩២.៤៣៦ | ២.៤១០.០៣០ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៥ | - | - | (១៧៩.៧៥៤) | (៧៣១.២៣៩) |
| **(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ** | | **(១.១៩២.១៤៦)** | **(៤.៨៧២.៣០០)** | ៤១២.៦៨២ | ១.៦៧៨.៧៩១ |
| ខាតលម្អិតផ្សេងៗ - | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **៣៤៧.៣៦៣** | - | ១៦៦.៣១៨ |
| **(ខាត)/ចំណូលលម្អិតផ្សេងៗសរុបក្នុងការិយបរិច្ឆេទ** | | **(១.១៩២.១៤៦)** | **(៤.៥២៤.៩៣៧)** | ៤១២.៦៨២ | ១.៨៤៥.១០៩ |

(ខាត)/ចំណេញក្នុងមួយសន្លឹកហ៊ុន ដែលបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| (ខាត)/ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន | **២៩** | (០.០៦) | (០.២៥) | ០.០៣ | ០.១៣ |
| (ខាត)/ចំណេញថយចុះក្នុងមួយភាគហ៊ុន | **២៩** | (០.០៦) | (០.២៥) | ០.០៣ | ០.១៣ |

# របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល

| | ដើមទុន | | បុព្វលាភដើមទុន | | ប្រាក់ចំណេញរក្សាទុក | | រូបិយប័ណ្ណប្តូរបម្រុងទុក | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣ និង២៧) (បានចាត់ថ្នាក់ឡើងវិញ) | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | | | | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | **២.២៨១.៦៦៤** | **៩.៤៤១.៨៨៧** | **(១២៧.០៤៧)** | **៩.០៥៥.២០៣** | **៣៦.៨៩០.៨៩៧** |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | (១.១៩២.១៨៦) | (៤.៨៧២.៣០០) | - | (១.១៩២.១៨៦) | (៤.៨៧២.៣០០) |
| ភាគលាភ | - | - | - | - | (២០៨.១២៨) | (៨៥០.៦១៩) | - | (២០៨.១២៨) | (៨៥០.៦១៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ៣៤៧.៣៦៣ | - | ៣៤៥.៣៦៣ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | **៨៨១.៣៥០** | **៣.៧១៨.៩៦៨** | **២២០.៣១៦** | **៧.៦៥៤.៩២៩** | **៣១.៥១៥.៣៤១** |
| | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៣.០០០.០០០ | ១២.២២៥.៣០១ | - | - | ១.៨៦៨.៩៨២ | ៧.៧៦៣.០៩៦ | (២៩៣.៣៦៥) | ៤.៨៦៨.៩៨២ | ១៩.៦៩៥.០៣២ |
| ការបន្ថែមដើមទុន | ១.៦១៥.៣៨៥ | ៦.៥៧១.៣៨៦ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | - | - | - | ៣.៧៧៣.៥៣៩ | ១៥.៣៥០.៧៥៦ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | ៤១២.៦៨២ | ១.៦៧៨.៧៩១ | - | ៤១២.៦៨២ | ១.៦៧៨.៧៩១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ១៦៦.៣១៨ | - | ១៦៦.៣១៨ |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | ២.២៨១.៦៦៤ | ៩.៤៤១.៨៨៧ | (១២៧.០៤៧) | ៩.០៥៥.២០៣ | ៣៦.៨៩០.៨៩៧ |

# របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល

| | កំណត់សម្គាល់ | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | (បានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | (១.១៩២.១៤៦) | (៤.៨៧២.៣០០) | ៥៩២.៤៣៦ | ២.៤១០.០៣០ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់លើទ្រព្យរូបី និងអរូបី | ៦.៧ និង ៨ | ១៨៩.៨៣៦ | ៧៧៥.៨៦៣ | ១៧៨.៩១៦ | ៧២៧.៨៣១ |
| ចំណាយហិរញ្ញវត្ថុ | ២៤ | ៣៥៤.៦០២ | ១.៤៤៩.២៥៨ | ៥០៦.៨៧០ | ២.០៦១.៩៤៧ |
| ខាតលើការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ២៣ | ៤៣៨ | ១.៧៩១ | ១.៨២០ | ៧.៤០៤ |
| (ខាត)/ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល | | (៦៤៧.២៧០) | (២.៦៤៥.៣៨៨) | ១.២៨០.០៤២ | ៥.២០៧.២១២ |
| **បម្រែបម្រួលទុនបង្វិល** | | | | | |
| បម្រែបម្រួលសុទ្ធក្នុង៖ | | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | | (៥៤៧.៤០៦) | (២.២៣៧.២៤៨) | (៦៤០.៥៣៦) | (២.៦០៥.៧០០) |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | | (១១៥.២៧៥) | (៤៧១.១២៩) | (៤៨៩.៤៨៦) | (១.៩៩១.២២៩) |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | | (១.៨៤៩) | (៧.៥៥៧) | (១៣៤.៤២១) | (៥៤៦.៨២៥) |
| សន្និធិ - សុទ្ធ | | ៨៩៣.១២៦ | ៣.៦៥០.២០៦ | (៥៣៣.៤៤២) | (២.១៧០.០៤២) |
| ប្រាក់តម្កល់ធានា | | (៥២៥.០៨០) | (២.១៤៦.០០២) | ១៤៥.៥៤៥ | ៥៩២.០៧៧ |
| គណនីពាណិជ្ជត្រូវទទួល | | ៣.១០៧.២៨៤ | ១២.៦៩៩.៤៧០ | (៤.៧៨៥.៨៣៨) | (១៩.៤៦៨.៧៨៩) |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | | (៥០) | (២០៤) | ៣៩.០០០ | ១៥៨.៦៥២ |
| ឥណទានវិបារូបន៍ | | ៥៣៩.៨៧២ | ២.២០៦.៤៥៧ | ១៤៦.៥២០ | ៥៩៦.០៤៣ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | | (៦៩៧.០៧១) | (២.៨៤៨.៩២៨) | ១.១៣៤.០៤៧ | ៤.៦១៣.៣០៣ |
| បំណុលកិច្ចសន្យា | | ១.៩៤៣.៣៧៤ | ៧.៩៤២.៥៧០ | (២៤៦.០៧៣) | (១.០០១.០២៥) |
| សមតុល្យដែលជំពាក់ភាគហ៊ុនិក | | - | - | (៥.៦៤២) | (២២.៩៥២) |
| **សាច់ប្រាក់បានពី/(បានប្រើក្នុង)សកម្មភាពប្រតិបត្តិការ** | | ៣.៩៤៩.៦៥៥ | ១៦.១៤២.២៤៧ | (៤.០៩០.២៨៤) | (១៦.៦៣៩.២៧៥) |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | ២៥ | (៧៧.៤២២) | (៣១៦.៤២៤) | (១៧២.៩៤៣) | (៧០៣.៥៣២) |
| **សាច់ប្រាក់សុទ្ធបានពី/(បានប្រើក្នុង)សកម្មភាពប្រតិបត្តិការ** | | ៣.៨៧២.២៣៣ | ១៥.៨២៥.៨២៣ | (៤.២៦៣.២២៧) | (១៧.៣៤២.៨០៧) |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | ៦ និង ៧ | (១.៦២៧.៩៦៥) | (៦.៦៥៣.៤៩១) | (១៨២.៨០៦) | (៧៤៣.៦៥៥) |
| ចំណូលពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | ៦ និង ៧ | - | - | ១៥០ | ៦១០ |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | (១.៦២៧.៩៦៥) | (៦.៦៥៣.៤៩១) | (១៨២.៦៥៦) | (៧៤៣.០៤៥) |

# របាយការណ៍លំហូរសាច់ប្រាក់ចន្លោះពេល (ត)

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | (បានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ១២ខែដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | ៦ និង ៧ | (១.៦២៧.៩៦៥) | (៦.៦៥៣.៤៩១) | (១៨២.៨០៦) | (៧៤៣.៦៥៥) |
| ចំណូលពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ និង ៧ | - | - | ១៥០ | ៦១០ |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | (១.៦២៧.៩៦៥) | (៦.៦៥៣.៤៩១) | (១៨២.៦៥៦) | (៧៤៣.០៤៥) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការបន្ថែមដើមទុន | ១៦ | - | - | ៣.៧៧៣.៥៣៩ | ១៥.៣៥០.៧៥៧ |
| ការទូទាត់សងប្រាក់កម្ចី | ១៦ | (៥.៦៨៧.៩១៩) | (២៣.២៤៦.៥២៥) | (៧.៣០៥.៥២១) | (២៩.៧១៨.៨៥៩) |
| ការទទួលបានប្រាក់កម្ចី | ១៧ | ៣.៨៥១.២៣៤ | ១៥.៧៣៩.៩៩៣ | ៨.៤៨៦.៨២១ | ៣៤.៥២៤.៣៨៨ |
| ការទូទាត់ភាគលាភ | ១៦ | (២០៨.១២៨) | (៨៥០.៦១៩) | - | - |
| ការទូទាត់ការប្រាក់ | ១៧ | (៣៥២.៧១១) | (១.៤៤១.៥២៩) | (៤៩៩.៧៦០) | (២.០៣៣.០២៤) |
| ការទូទាត់សងបំណុលភតិសន្យា | ៨ | (៥០.៤០០) | (២០៥.៩៨៥) | (៦៧.២០០) | (២៧៣.៣៧៤) |
| **សាច់ប្រាក់សុទ្ធបានពី/(បានប្រើក្នុង)សកម្មភាពហិរញ្ញវត្ថុ** | | (២.៤៤៧.៩២៤) | (១០.០០៤.៦៦៥) | ៤.៣៨៧.៨៧៨ | ១៧.៨៤៩.៨៨៨ |
| | | | | | |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធក្នុងអំឡុងការិយបរិច្ឆេទ** | | (២០៣.៦៥៥) | (៨៣២.៣៣៥) | (៥៨.០០៥) | (២៣៥.៩៦៥) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលអំឡុងដើមការិយបរិច្ឆេទ | | ២២៥.១១៩ | ៩១៧.១៣៥ | ២៨៣.១២៤ | ១.១៤៥.២៣៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៣.៥៦៧ | - | ៧.៨៦៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ** | | ២១.៤៦៤ | ៨៨.៣៦៧ | ២២៥.១១៩ | ៩១៧.១៣៥ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ១. អំពីក្រុមហ៊ុន

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ដែលពីមុនត្រូវបានគេស្គាល់ថាជាក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ឯ.ក) ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ មានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៤០២៩ នៅក្រសួងពាណិជ្ជកម្ម។ ដោយអនុលោមតាមអនុស្សរណៈ និងលក្ខន្តិកៈ ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន គឺរយៈពេល ៩៩ឆ្នាំ គិតចាប់ផ្តើមពីកាលបរិច្ឆេទចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ("MoC") នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជី និងទីតាំងអាជីវកម្មចម្បងរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅដីឡូតិ៍លេខ៦៨ ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ប្រអប់សំបុត្រ ១៧៨ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានប្តូរឈ្មោះពី ឌី ប៊ី ឌី អ៊ិនជីនារីង ឯ.ក ទៅជា ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បន្ទាប់ពីទទួលបានការអនុម័តពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺ ធ្វើប្រតិបត្តិការជាអ្នកម៉ៅការផ្នែកមេកានិក និងអគ្គិសនី អ្នកម៉ៅការប្រព័ន្ធទឹក និងពន្លត់អគ្គិភ័យ ប្រព័ន្ធម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ HVAC និងអ្នកម៉ៅការថែទាំអគារផ្សេងៗ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ក្រុមហ៊ុនមាននិយោជិតចំនួន ១១១២ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ មានចំនួន៩៦៦ នាក់)។

នៅថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០២១ ក្រុមហ៊ុនបានចុះបញ្ជីដោយជោគជ័យនៅក្នុងទីផ្សារកំណើននៃផ្សារមូលបត្រកម្ពុជា។ ចំនួនហ៊ុនថ្មីដែលបានបោះផ្សាយមានចំនួន ៦.៤៦១.៥៣៨ ហ៊ុន ជាមួយតម្លៃចារឹក ១០០០ រៀល ឬ ០.២៥ ដុល្លារអាមេរិក ក្នុងមួយហ៊ុន ក្នុងតម្លៃលក់ចេញ ២.៣៨០ រៀល ឬ ០.៥៩០ ដុល្លារក្នុងមួយហ៊ុន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ អនុស្សរណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុនកំពុងត្រូវបានធ្វើបច្ចុប្បន្នភាព។

## ២. មូលដ្ឋាននៃការរៀបចំ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ត្រីមាសដែលបានបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ("CIAS ៣៤")។ ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលកំណត់សម្គាល់ទាំងអស់ដូចនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចប្រចាំឆ្នាំនោះទេ។ ដូច្នេះរបាយការណ៍នេះត្រូវអានដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដែលត្រូវបានរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។ គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺស្របតាមគោលនយោបាយគណនេយ្យសំខាន់ៗដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

## ៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាប្រាក់ដុល្លារអាមេរិក ក្រុមប្រឹក្សាភិបាលបានកំណត់យកប្រាក់ដុល្លារអាមេរិក ("USD") ជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងក្នុងការវាស់វែង និងបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃសេដ្ឋកិច្ចក្រោមព្រឹត្តិការណ៍ និងស្ថានការណ៍របស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ក្រៅពីប្រាក់ដុល្លារអាមេរិក គឺត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ក្នុងអត្រាប្តូរប្រាក់ស្ថិតនៅកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុ ដែលកំណត់ដោយរូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិកនាកាលបរិច្ឆេទរបាយការណ៍ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ លម្អៀងនៃអត្រាប្តូរប្រាក់ គឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត។

ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាខ្មែររៀល បានបង្ហាញនៅក្នុងព័ត៌មានហិរញ្ញវត្ថុត្រូវបានធ្វើឡើង គឺដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជា (ខែមេសា ឆ្នាំ២០១៦) ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការ ដោយផ្អែកលើអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិកដែលបានចេញផ្សាយដោយធនាគារជាតិ នៃ កម្ពុជា ("NBC")៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ |
|---|---|---|
| អត្រាជាមធ្យម* - ៣ខែ | **៤.១២៩** | ៤.០៧០ |
| អត្រាជាមធ្យម* - ១២ខែ | **៤.០៨៧** | ៤.០៦៨ |
| អត្រាចុងគ្រា | **៤.១១៧** | ៤.០៧៤ |

*អត្រាជាមធ្យម គឺត្រូវបានគណនាដោយប្រើប្រាស់អត្រាប្រចាំថ្ងៃរបស់ធនាគារជាតិ នៃ កម្ពុជា ក្នុងអំឡុងការិយបរិច្ឆេទនេះ។

ការប្តូររូបិយប័ណ្ណទាំងនេះមិនត្រូវបានធ្វើសវនកម្មទេ ហើយមិនត្រូវបានបកស្រាយថាជាតំណាងនៃប្រាក់ដុល្លារអាមេរិក ដែលត្រូវបាន ឬអាចនឹងត្រូវបាន ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

### ប្រតិបត្តិការ និងសមតុល្យនៃរូបិយប័ណ្ណបរទេស

សមាសធាតុមិនមែនជារូបិយវត្ថុ គឺមិនត្រូវបានប្តូរឡើងវិញនាចុងការិយបរិច្ឆេទទេ និងត្រូវបានវាស់វែងតាមថ្លៃដើមប្រវត្តិសាស្ត្រ (បានប្តូររូបិយប័ណ្ណដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការ) លើកលែងសម្រាប់សមាសធាតុមិនមែនរូបិយវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប ដែលត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់នាកាលបរិច្ឆេទដែលតម្លៃសមស្របត្រូវបានកំណត់។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យ និងវិធីសាស្ត្រគណនាដែលបានអនុម័ត គឺស្របទៅជាមួយនឹងវិធីសាស្ត្រដែលបានអនុម័តក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

## ៥. ការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង

នៅពេលរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល គណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតជាច្រើនអំពីការទទួលស្គាល់ និងវាស់វែងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ។ លទ្ធផលជាក់ស្តែងអាចខុសពីលទ្ធផលនៃការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលបានធ្វើឡើងដោយគណៈគ្រប់គ្រង ហើយកម្រនឹងស្មើលទ្ធផលដែលបានប៉ាន់ស្មាន។

ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត ដែលបានអនុវត្តនៅក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងប្រភពសំខាន់ៗនៃភាពមិនប្រាកដប្រជានៃការប៉ាន់ស្មាន គឺដូចគ្នាទៅនឹងអ្វីដែលបានអនុវត្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

(ទំព័រនេះត្រូវទុកឲ្យចន្លោះទទេដោយចេតនា)

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ

បម្រែបម្រួលសមតុល្យយោងរបស់ទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | ដី<br>ដុល្លារអាមេរិក | គ្រឿងម៉ាស៊ីន<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម<br>ដុល្លារអាមេរិក | ការកែលម្អដី<br>ដុល្លារអាមេរិក | អគារកំពុងសាងសង់<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | <br>ពាន់រៀល<br>(កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|---|---|---|---|
| (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | | | | | | | | |
| សមតុល្យយោងដុល | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ២.១៦៧.៦២០ | ៦៥២.៩៤០ | ៥៧៣.៤០៩ | ៦៦.៤៣៣ | ៨.៩០៩ | ៥២.១៦៦ | ៦០.៨០១ | ៣.៥៨២.២៧៨ | ១៤.៥៩៤.២០១ |
| ទិញបន្ថែម | - | ៩៣.៥២៥ | - | ៦.២៤០ | - | - | ១.៥១៣.៣៩១ | ១.៦១៣.១៥៦ | ៦.៥៩២.៦៦៩ |
| លុបចេញពីបញ្ជី និងការលក់ចេញ | - | (១៣.២០៥) | - | (៤.០៤៣) | - | - | - | (១៧.២៤៨) | (៧០.៤៩៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២០១.៩១៤ |
